# រឿងកែវមរកត

( ចាក រ. វ. )

( ព្រះកែវមរកត ជាមរកតរបស់ប្រទេសកម្ពុជា )

ព្រះ កែវមរកត កើតឡើងក្នុងព.ស.៥០០ កើតដោយអានុភាពរបស់ព្រះនាគសេនត្ថេរជាព្រះអរហន្ត ដែលគង់នៅក្នុងអសោការាម នាក្រុងបាតលីបុត្ត ដែនមគធៈ ។ ព្រះអរហន្តទាំងនេះ មានបំណងចង់ក៏សាងព្រះពុទ្ធបដិមា. បំណងនោះក៏ជ្រាបដល់ព្រះឥន្ទ្រ ៗ ទ្រង់ជ្រះថ្លាក្នុងការកសាងនេះដែរ ទើបត្រាស់ប្រើវិស្សុកម្មទេវបុត្រ ឱ្យទៅយកកែវមណីជោតិ នៅភ្នំវេបុល្ល ដែលពួកកុម្ភណ្ឌថែរក្សា ។

ពួកកុម្ភណ្ឌ មិនហ៊ានថ្វាយកែវមុណីជោតិនោះឡើយ ដោយខ្លាចក្រែងមានស្តេចចក្កពត្រាធិរាជកើតឡើង មិនបានយកកែវមណីជោតិទៅថ្វាយនឹងបែកក្បាលជា ៧ ភាគ ។ វិស្សុកម្មទេវបុត្រ ក៏ត្រឡប់ទៅក្រាបទូលព្រះឥន្ទ្រវិញតាមដំណើរ

ព្រះឥន្ទ្រ កាលបើមិនបាននូវកែវមណីជោតិនោះហើយ ទើបស្តេចយាងទៅកាន់ភ្នំវេបុល្លជាមួយនឹងវិស្សុកម្មទេវបុត្រ ។ ពួកកុម្ភណ្ឌទាំងឡាយ ក៏ក្រាបទូលតាមហេតុដែលថ្វាយមិនបាន ។ ព្រះឥន្ទ្របានសួររកកែវដ៏ទៃទៀត ដែលល្អបន្ទាប់ពីកែវមណីជោតិ ។ កុម្ភណ្ឌក្រាបទូលថា មានកែវមរកតមួយដុំ ពណ៌ដូចត្រួយចេកនៅបាទភ្នំវេបុល្ល ជាកែវឥតម្ចាស់ ។

ព្រះឥន្ទ ក៏ប្រើពួកកុម្ភណ្ឌឱ្យទៅយក កែវមរកតនោះមកថ្វាយ លុះបានហើយទើបយកទៅប្រគេនព្រះនាគសេនត្ថេរ ៗ មិនអាចរកជាងឆ្លាក់បានឡើយ ព្រះកែវនោះរឹងពេក ។  ព្រះឥន្ទ្របានជ្រាបដំណឹងនោះ ក៏ប្រើវិស្សុកម្មទេវបុត្រឱ្យទៅឆ្លាក់ប្រគេន ដោយហេតុថាវិស្សុកម្មទេវបុត្រ ធ្លាប់ឃើញព្រះសម្ពុទ្ធកាលគង់ព្រះជន្មនៅ អាចឆ្លាក់ព្រះពុទ្ធរូប មានលក្ខណៈប្រហែលនឹងតួអង្គព្រះសម្ពុទ្ធដោយច្រើន ។

ព្រះពុទ្ធរូបព្រះកែវមរកតនោះមានកំពស់មួយហត្ថ ៧ ធ្នាប់ ព្រះភ្នែន ២៣ ធ្នាប់ ។ ព្រះនាគសេនត្ថេរ បានបញ្ចុះបរមធាតុ ៧ អង្គ ទៅក្នុងព្រះកែវមរកតនោះគឺ បញ្ចុះនៅព្រះសិរ ១ អង្គ ព្រះនលាដ ១  អង្គ ព្រះឧរា ១ អង្គ ព្រះអង្សាស្មាស្តាំ ១ អង្គ ឆ្វេង ១ អង្គ ព្រះជង្ឃស្មងស្តាំ ១ អង្គ ឆ្វេង ១ អង្គ  លុះកសាងហើយស្រេច ពុទ្ធ

បរិស័ទទាំងឡាយមានព្រះនាគសេនត្ថេរជាប្រធាន បានចាត់ធ្វើមណ្ឌប ប្រតិស្ឋានព្រះកែវមរកតនោះ  នៅក្រុងបាតលីបុត្រ ហើយមានការសម្ពោធ អភិសេកជាឱឡារិក ។

តមក ក្នុងរជ្ជកាលព្រះបាទសិរិកិត្តិរាជរវាង ព.ស. ១០០០ប្រទេសមគធៈកើត ចលាចលបះបោរដណ្តើមរាជសម្បត្តិ ឯព្រះពុទ្ធសាសនាក៏រៀវរោយថយចុះជា ច្រើន ទើបពុទ្ធបរិស័ទមួយក្រុម និមន្តព្រះកែវមរកតចុះសំពៅបើកសំដៅទៅ កោះលង្កា  ដោយមានបំណងយកព្រះកែវមរកតទៅទុកនៅទីនោះ ឱ្យផុតពី កណ្តាប់ដៃពួកជនមច្ឆាទិដ្ឋិ ទៅដល់កោះលង្កា ពុទ្ធបរិស័ទ ទាំងឡាយមានព្រះ មហាក្សត្រត្រិយ៍ និងព្រះសង្ឃបរិនាយកជាដើម បានទទួលព្រះកែវមរកត ហែរ ទៅប្រតិស្ឋាននៅវត្តមេឃគិរីមហាវិហារ ដែលជាវត្តសំខាន់បំផុតក្នុងទីក្រុង ។

ពេលនោះព្រះពុទ្ធសាសនានៅកោះលង្កា រុងរឿងជាងនានាប្រទេស មានគម្ពីរ ព្រះត្រៃបិដកគ្រប់គ្រាន់បរិបូណ៌ទាំងបែបភាសាបាលីទាំង បែបភាសាលង្កា ។ ត មកក្នុង ព.ស. ១៥៦០ ប្រទេសភូមាមានព្រះមហាក្សត្រិយ៍មួយអង្គនាមអនុរុទ្ធ ជា អគ្គពុទ្ធសាសនូបត្ថម្ភ ក៏ទ្រង់បានជ្រាបថា នៅកោះលង្កា មានព្រះត្រៃបិដកចប់ បរិបូរណ៌  ទើបទ្រង់ឱ្យតាក់តែងសំពៅពីរ ហើយស្តេចយាងចុះសំពៅទៅលង្កាទ្វីប ជាមួយនឹងអ្នកប្រាជ្ញច្រើនរូបមានទាំងបព្វជិតទាំងគ្រហស្ថ ដើម្បីចម្លងព្រះត្រៃ បិដក លុះទៅដល់កោះលង្កាហើយ ស្តេចយាងចូលទៅគាល់ព្រះចៅកោះលង្កា ព្រះនាមលង្កិស្សររាជ ។

ព្រះចៅកោះលង្កា ទ្រង់ធ្វើបដិសណ្ឋារៈកិច្ចយ៉ាងខ្ពង់ខ្ពស់ លុះទទួលបដិសណ្ឋារៈ កិច្ចរួចហើយ ស្តេចយាងទៅថ្វាយបង្គំព្រះសង្ឃបរិនាយក នៅវត្តមេឃគិរីមហា វិហារ សុំចម្លងព្រះត្រៃបិដក ជាភាសាបាលីមួយចប់ ភាសាលង្កាមួយចប់ចម្លង ស្រេចហើយព្រះបាទអនុរុទ្ធ ទ្រង់សុំព្រះកែវមរកតយកទៅប្រតិស្ឋានទុកនៅ ប្រទេសភូមិមាជាទីរលឹក ។

ព្រះបាទលង្កិស្សររាជ បានថ្វាយព្រះកែវមរកតដល់ព្រះបាទអនុរុទ្ធតាមសេចក្តីសុំ ទើបព្រះអនុរុទ្ធត្រាស់បង្គាប់ឱ្យជញ្ជូនព្រះត្រៃបិដកភាសាបាលីដាក់ សំពៅមួយ ព្រះត្រៃបិដកជាភាសាលង្កានិងព្រះកែវមរកតដាក់សំពៅមួយចំណែក ព្រះអង្គគង់ សំពៅដែលដាក់ព្រះត្រៃបិដកភាសាបាលី ។ សំពៅទាំងពីរបានបើកចេញពីកោះ

លង្កា សំដៅទៅប្រទេសភូមា ដល់ពាក់កណ្ដាលមហាសាគរ សំពៅដែលដឹកលល់ព្រះត្រៃបិដកភាសាលង្កានិងព្រះកែវមរកត ត្រូវខ្យល់ព្យុះបោកបក់រសាត់មកជាប់នៅត្រើយសមុទ្រត្រង់ជាយខែត្រ បន្ទាយមាស នៃប្រទេសកម្ពុជាភាគខាងត្បូង រាជការខែត្របន្ទាយមាស ចាប់សំពៅនោះបាន ទើបនាំយកគម្ពីរព្រះត្រៃបិដក និងព្រះកែវមរកតទៅថ្វាយព្រះបាទសូរ្យវង្ស៍ទី១ នៅក្រុងស្រីសោធបុរៈ. ទ្រង់ស្ដេចទតឃើញព្រះកែវមរកតនោះ ទ្រង់សោមនស្សណាស់ បានឱ្យសាងវិហារមួយ ដំកល់ទុក ខាងក្នុងព្រះបរមរាជវាំង ។

ថ្ងៃក្រោយព្រះបាទអនុរុទ្ធបានជ្រាបដំណឹង ទើបប្រើរាជបំរើឱ្យនាំសារមកសុំយករបស់ទាំងនោះទៅវិញ ។ ព្រះបាទសូរ្យវង្ស៍ទី១ បានប្រគល់តែព្រះត្រៃបិដកឱ្យវិញ ទ្រង់ទុកព្រះកែវមរកត ពុំបានថ្វាយដល់ព្រះអនុរុទ្ធព្រះចៅភូមាឡើយ ព្រោះទ្រង់សព្វព្រះរាជហឫទ័យមនស្សជ្រះថ្លា ចំពោះព្រះកែវមរកតនោះ ក្រៃពេក ។

ព្រះកែវមរកត ក៏បានមកជាមតិកប្រទេសកម្ពុជាក្នុងវេលានោះដោយសេរី ឥតបានដឹងបានប្រាថ្នា ឬសូមអំពីសណាក់បុគ្គលណាឡើយ ។

វាយអត្ថបទដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ យ៉ែម ភិរុណ ដកស្រង់ចេញប្រជុំនិទានជាតកភាគ១ របស់ព្រះបាឡាត់ឧត្ដមលិខិត សុង ស៊ីវ សិទ្ធត្ថោ គ្រូបង្រៀនបាលីនៅវត្តលង្កា រាជធានីភ្នំពេញ ។ អរព្រះគុណព្រះភិក្ខុ សិរីប

សូមអស់លោកអ្នកអនុមោទនា !

ចប់